# ព្រះរាជក្រម

នស/រកម/១២០៦/០៣៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧
# នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

**មាត្រាមួយ.-**

មាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ១៤ .- ថ្មី**

១-សមាជិកនៃក្រុមប្រឹក្សា ត្រូវតែជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍ និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានអាយុមិនលើសពី ៦៥ ឆ្នាំ ។ សមាជិកទាំងនោះត្រូវបានតែងតាំងសម្រាប់រយៈពេល ៤ ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបាន ។ ចំពោះក្រុមប្រឹក្សាលើកទី ១ ដែលបង្កើតតាមច្បាប់នេះ លើកលែងតែទេសាភិបាល ទេសាភិបាលរង និងតំណាងឱ្យបុគ្គលិកធនាគារកណ្តាល អាណត្តិរបស់សមាជិក ២ រូប ត្រូវចប់ក្នុងរយៈពេល ២ ឆ្នាំ ក្រោយពីថ្ងៃតែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងគ្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុណាមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២_សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក_ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាល ឬពីបទល្មើសផ្នែកសេដ្ឋកិច្ច ឬ ផ្នែកពាណិជ្ជកម្ម ។

ខ_មានសេចក្តីសម្រេចពីក្រុមប្រឹក្សាថាបានប្រព្រឹត្តបំពានទៅលើការហាមឃាត់ ដែលចែងក្នុងមាត្រា ១៥ និង១៦ នៃច្បាប់នេះ ។

គ_អវត្តមានក្នុងការប្រជុំជាប់ៗគ្នា ៤ ដង លើកលែងតែមានជំងឺ និងក្នុងករណីប្រធានស័ក្តិ ដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ_លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង_មិនអាចបំពេញភារកិច្ចរបស់ខ្លួនបាន ដោយបាត់បង់សមត្ថភាពពលកម្ម និងវិបត្តិស្មារតី ។

ច_ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣_ការប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើយ៉ាងហោចណាស់ ២ ខែ ម្តង ។

៤_សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃក្បាច់វត្តមាន ដែលក្រុមប្រឹក្សាជាអ្នកកំណត់ ។

៥_ទេសាភិបាល និងទេសាភិបាលរងទទួលប្រាក់តម្លៃការជាមូលដ្ឋានពីធនាគារកណ្តាលស្មើនឹងសមាជិកនៃរាជរដ្ឋាភិបាល ។

4

15

**មាត្រា ៥៧ .- ថ្មី**

ការត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា-ភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ពរល.០៦១២.៥៥៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខ : ១៧. ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**